# លោកតាពជ្យ ដើមកំណើត និងជំនឿ

បើនិយាយអំពី ***លោកតាពជ្យ*** មនុស្សភាគច្រើនតែងនឹកគិតទៅបដិមាដៃ៨ដ៏ធំមួយនៅក្នុងបន្ទប់ខាងត្បូង នៃច្រកចូលខាងលិចរបស់ប្រាសាទអង្គរវត្ត។ អ្នកស្រុកដើមក្នុងតំបន់អង្គរតែងគោរពបដិមានេះយ៉ាងខ្ជាប់ខ្ជួន និងមានជំនឿថាជាអ្នកតាដ៏មានរិទ្ធីគ្រប់គ្រងក្នុងបរិវេណប្រាសាទអង្គរវត្ត ជាពិសេសនៅប្រចាំទិសខាងលិច ឬក្លោងទ្វារចូលខាងលិច។ ក្រៅពីលោកតាពជ្យ មានអ្នកតា៣ផ្សេងទៀតដែលចាំនៅតាមក្លោងទ្វារចូលដទៃ ដូចជា ***អ្នកតាលោកតាឡឹក*** នៅទិសខាងជើង ***អ្នកតាគោកគូ*** នៅទិសខាងកើត និង ***អ្នកតាពេជ្រ*** នៅទិសខាងត្បូង។ ប៉ុន្តែអ្នកតាទាំង៣នេះមានតែឈ្មោះ ពុំមានរូបជាតំណាងធំដុំដូចលោកតាពជ្យទេ។

ពាក្យ ***លោកតាពជ្យ*** គឺជាឈ្មោះដែលអ្នកស្រុកបានដាក់អោយ និងហៅតាមចម្លាក់បដិមាជាទេពដ៏ធំមានព្រះហស្ត៨។ បដិមានេះត្រូវបានគេជឿថា ជា***ទេពព្រះវិស្ណុ*** ពិសេសគឺបដិមាព្រះវិស្ណុដែលតម្កល់នៅប្រាង្គកណ្ដាល (បាកាណ) របស់ប្រាសាទអង្គរវត្ត ហើយត្រូវបានគេរំកិលយកមកដាក់នៅបន្ទប់ខាងត្បូង នៃក្លោងទ្វារខាងលិចនេះ។ ចំពោះពត៌មានអំពីការចល័តបដិមានេះពីប្រាង្គកណ្ដាលមកកន្លែងសព្វថ្ងៃនេះ គឺជាការនិយាយតគ្នាពុំមានភស្តុតាងជាឯកសារ ឬសិលាចារឹកណាមួយបរិយាយឡើយ។ បើយើងពិនិត្យមើលតាមរយៈរូបថតរបស់បារាំងឃើញថា បដិមាលោកតាពជ្យមាននៅក្នុងបន្ទប់ខាងត្បូងនេះរួចទៅហើយ (រូបលេខ១[១]) បដិមានៅរក្សាស្ថានភាពដើមស្ទើរទាំងស្រុង ពុំមានបែកបាក់ព្រះហស្តទេ ហើយក្នុងឆ្នាំ១៩៤៩ បារាំងបានស្ទូចឡើងបន្តិចដើម្បីពិនិត្យមើលផ្នែកខាងក្រោម (រូបលេខ២[២])។ ក្រោយទសវត្សទី៨០ បដិមានេះត្រូវបានជនទុច្ចរិតវាយបំបាក់ព្រះកេសដើម្បីយកទៅលក់ តែដោយសារមិនអាចយកទៅបាន ព្រះកេសត្រូវបានវាទុកចោល

[១] https://collection.efeo.fr/ws/web/app/collection/record/220720

[២] https://collection.efeo.fr/ws/web/app/collection/record/217424

នៅក្បែរនោះ។ ក្នុងឆ្នាំ១៩៩៣ គេបានយកព្រះកេសនោះទៅរក្សាទុកនៅក្នុងរាជវាំងក្រុងភ្នំពេញ ហើយបន្ទាប់មកទៀត គេយកមករក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ។ ក្នុងឆ្នាំ ២០០៤ អាជ្ញាធរអប្សរា សហការជាមួយក្រុមបច្ចេកទេសអាល្លឺម៉ង់បាននាំយកព្រះកេសនោះមកជួសជុលតភ្ជាប់ជាមួយដងខ្លួនវិញ។ ចំណែកព្រះហស្តខាងស្តាំ១ និងខាងឆ្វេង២ ដែលបានបាត់ គឺជំនួសដោយថ្មភក់ថ្មី។

## តើលោកតាពជ្យ ឬបដិមាលោកតាពជ្យជានរណា?

ទាំងអ្នកស្រាវជ្រាវ និងមនុស្សទូទៅមួយចំនួនធំ ពិសេសគឺអ្នកមកពីតំបន់ឆ្ងាយតែងតែជឿតគ្នាថា លោកតាពជ្យគឺជាបដិមាព្រះវិស្ណុដៃ៨ ជាបដិមាដើមរបស់ប្រាសាទអង្គរវត្ត ហើយត្រូវបានគេចល័ត[៣] យកមកតម្កល់នៅក្នុងបន្ទប់ខាងត្បូងរបស់ច្រកចូលខាងលិចនេះ។ យើងមានចំនុច២គួរពិចារណា គឺ៖

(១) បដិមានេះ ***អាចជាព្រះវិស្ណុ*** ព្រោះមានដៃ៨ ដូចគ្នាទៅនិងបដិមាព្រះវិស្ណុនៅប្រាសាទភ្នំដា ដែលគេហៅថា វិស្ណុកម្ពុជេន្ទ្រ (រូបលេខ៣)។[៤] ម្យ៉ាងទៀត តាមកេតនកណ្ឌនៅលើដៃខាងស្តាំ ខាងលើបង្អស់ គឺមានរាងដូចកងចក្រ ដែលជាអាវុធរបស់ព្រះវិស្ណុ ប៉ុន្តែដៃផ្សេងៗទៀតមានតែវត្ថុមូលទ្រវែង ដូចទៅនឹងគម្ពីរក្នុងដៃរបស់ទេពអវលោកិតេស្វរៈ។ ក្នុងករណីជាបដិមាព្រះវិស្ណុដដែល បដិមានេះត្រូវបានស្ថាបនាឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ឬក្នុងរចនាបថបាយ័ន្ត ហើយទីតាំងដើម គឺឋិតនៅក្នុងបន្ទប់ខាងត្បូងនេះតែម្តង។

(២) ករណីទី២ បដិមាលោកតាពជ្យនេះ***អាចមិនមែនជាទេពព្រះវិស្ណុទេ***។ ការសិក្សាលើកាយវិភាគសាស្ត្រ បដិមានេះ រួមទាំងបដិមាដទៃទៀតក្នុងបន្ទប់របស់ក្លោងទ្វារខាងលិចនេះ គឺជាអវលោកិតេស្វរៈ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។ ទម្រង់នៃទឹកមុខ ព្រះភ័ក្ត្រ និងកាយវិភាគសាស្ត្រ (ការសិក្សាលើរូបរាង) យើងអាចសន្និដ្ឋានបានថា បដិមាលោកតាពជ្យ

[៣] មានមនុស្សមួយចំនួនយល់ថា បារាំងជាអ្នកចល័តពីប្រាង្គកណ្តាលមកតំកល់ទីនោះ

[៤] Jean Boisselier, 1966:Pl XXXI

គឺមិនមែនជាបដិមាទេពវិស្ណុទេ គឺជាបដិមាអវលោកិតេស្វរៈ នៃពុទ្ធសាសនាមហាយានក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ (១១៨១គ.សដល់១២២០គ.ស) គឺពុំមែនជាបដិមាស្ថិតក្នុងរចនាបថអង្គរវត្ត ឬក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ (១១១៣គ.សដល់១១៥០គ.ស) ដែលបានស្ថាបនាប្រាសាទអង្គរវត្តនេះទេ។ ប្រាសាទអង្គរវត្តជាប្រាសាទដែលស្ថាបនាឡើងឧទ្ទិសជាសំខាន់ដល់ព្រះវិស្ណុ ប៉ុន្តែមិនមែនសម្រាប់តម្កល់បដិមាព្រះវិស្ណុនោះទេ គឺសម្រាប់តម្កល់ព្រះសពព្រះបាទសូរ្យវរ្ម័នទី២ (បរមវិស្ណុលោក) នៅប្រាង្គកណ្តាលតែម្តង។[៥] ក្រោយមក ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គប្រហែលគោរពដល់បុព្វបុរសរបស់ខ្លួន ហើយដោយសារព្រះអង្គបានកែប្រែជាពុទ្ធសាសនិកផងនោះ ព្រះអង្គបានមកស្ថាបនាពុទ្ធបដិមាជាច្រើន ដែលមានកស្តុតាងនៅតាមថែវទី២ និងរូតព្រះពាន់។ លើសពីនេះ ព្រះអង្គអាចអោយគេស្ថាបនាតំណាងព្រះរូបព្រះអង្គផ្ទាល់១ តម្កល់ក្នុងប្រាសាទអង្គរវត្តនេះ ហើយសព្វថ្ងៃបដិមានេះនៅសល់ត្រឹមតែកចុះមកក្រោម ពោលគឺបាត់ព្រះកេស ហើយស្ថិតនៅក្នុងថែវទី២ មុខខាងកើត ស្ថាបខាងត្បូង។ នៅច្រកចូលខាងលិចដែលជាច្រកសំខាន់ ព្រះអង្គបានអោយគេសាងបដិមាលោកេស្វរជាច្រើន រួមមាន៖ (១)បដិមាអវលោកិតេស្វរៈដៃ៨ (លោកតាពជ្យ) នៅបន្ទប់ខាងត្បូង (រូបលេខ២) (២)បដិមាលោកេស្វរៈដៃ៤ នៅខាងត្បូងលោកតាពជ្យ ហើយសព្វថ្ងៃត្រូវបានគេយល់ថាជាព្រះនាងលក្ស្មី ដោយរៀបចំស្លៀកពាក់អោយក្លាយជាបដិមាទេពស្រី តែគ្មានព្រះកេសទេ (រូបលេខ៥) (៣) បដិមាលោកេស្វរៈដៃ៤គ្មានព្រះកេស នៅចន្លោះបន្ទប់ខាងត្បូង និងបន្ទប់ច្រកចូលកណ្តាល (រូបលេខ៦) (៤) បដិមាអវលោកិតេស្វរៈដៃ៨មានព្រះកេស នៅចន្លោះបន្ទប់ច្រកចូលកណ្តាល និងបន្ទប់ខាងជើង (រូបលេខ៧) (៥) បដិមាអវលោកិតេស្វរៈដៃ១០ មានព្រះកេស នៅបន្ទប់ខាងជើង (រូបលេខ៨)។ តាមរយៈរូបរាង ទំហំ ទម្រង់ទឹកព្រះភ័ក្ត្រ និងសំលៀកបំពាក់ យើងអាចវាយតម្លៃថា បដិមាទាំងនេះស្ថិតក្នុងរចនាបថបាយ័ន្ត ក្នុងរាជ្យព្រះបាទជ័យវរ្ម័ន៧។ ម៉្យាងទៀត បើយើងប្រៀបធៀបជាមួយបដិមាមួយចំនួនដែលស្ថាប

[៥] សុខ កែវ សុវណ្ណារ៉ា, ២០២១

នាមិនទាន់ហើយ នៅភ្នំដី (អាចជាទីតាំងសិប្បកម្មចម្លាក់បដិមា) គឺមានលក្ខណៈដូចគ្នា គឺជាបដិមាស្ថិតក្នុងរចនាបថបាយ័ន្ត (រូបលេខ៩)។ បើយើងលើកយកហេតុផលកេតនកណ្ឌជាកងចក្រនៅលើដៃខាងស្តាំ ហើយកំណត់ថាជាព្រះវិស្ណុនោះ វាអាចមិនត្រូវទាំងស្រុង ព្រោះក្នុងពុទ្ធសាសនាមហាយាន តាមគម្ពីរ Kāraṇḍavyūha Sūtra[៦] គេយល់ថាទេពទាំងឡាយ គឺកើតចេញពីរាងកាយរបស់ព្រះអវលោកិតេស្វរៈ (ព្រះវិស្ណុកើតចេញពីបេះដូង)។ នៅលើចម្លាក់នេះ គេពុំបានឆ្លាក់ជារូបព្រះវិស្ណុតែម្តងទេ តែគេបង្ហាញកងចក្រដែលតំណាងអោយព្រះវិស្ណុ ដែលយើងមានចម្លាក់អវលោកិតេស្វរៈជាសំរឹទ្ធ១ មានព្រះហស្ត៨ និងកាន់កេតនកណ្ឌផ្សេងៗតំណាងអោយទេពនីមួយៗ ក្នុងនោះខ្យងស័ង្ខ នៅដៃខាងឆ្វេងលើបង្អស់តំណាងអោយព្រះវិស្ណុ (រូបលេខ១០[៧])។ លើសពីនេះ បើយើងប្រៀបធៀបបដិមាធំៗទាំង៣ ក្នុងបន្ទប់ច្រកចូលខាងលិចរបស់ប្រាសាទអង្គរវត្ត ជាមួយចម្លាក់ក្រឡោតទាបនៅជញ្ជាំងខាងត្បូងនៃថែវខាងលិចរបស់ប្រាសាទបន្ទាយឆ្មារ យើងឃើញថាបដិមាទាំងនេះមានលក្ខណៈដូចគ្នាខ្លះជាមួយ និងចម្លាក់ក្រឡោតទាប ពិសេសគឺអវលោកិតេស្វរៈដែលមានព្រះកេស១ ព្រះហស្ត៨ និងព្រះហស្ត១០ (រូបលេខ១១[៨])។

ចំនុចនេះបញ្ជាក់ថា បដិមាលោកតាពជ្យ និងបដិមាធំ២ទៀតក្នុងច្រកទ្វារខាងលិច គឺជាបដិមាអវលោកិតេស្វរៈក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ឬក្នុងរចនាបថបាយ័ន្ត។

## ជំនឿ និងកិច្ចប្រតិបត្តិ

តាមរយៈរូបថតចាស់របស់បារាំងបង្ហាញថា ទីកន្លែងលោកតាពជ្យ គឺជាទីសក្ការៈតូចមួយពុំមានការរៀបចំអោយស្អាត ឬមានសណ្តាប់ធ្នាប់អ្វីទេ។ ការគោរពនេះ គឺអាចមានតាំងពីសម័យកណ្តាលមកម្ល៉េះ ប៉ុន្តែដោយសារប្រជាជនអោយភាពសំខាន់ទៅទីខាង

---

[៦] Peter Alan Robert and Tulku Yeshi, 2013:29

[៧] https://commons.wikimedia.org/wiki/File:Cambodian

[៨] https://collection.efeo.fr/ws/web/app/collection/record/250167

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ក្នុងនៃប្រាសាទ ពិសេសប្រាង្គកណ្តាល(បាកាណ) និងរួតព្រះពាន់ ដូចនេះលោកតាពជ្យគ្រាន់តែជាកន្លែងគោរពបូជាតូចមួយប៉ុណ្ណោះ។ ព្រះនាម ***លោកតាពជ្យ*** ក៏ពុំដឹងប្រកពច្បាស់ថា តើប្រជាជនខ្មែរចាប់ផ្តើមហៅនៅពេលណាដែរ ហើយក្នុងឯកសារបារាំងក៏ពុំបានសរសេរថាលោកតាពជ្យដែរ គឺគេហៅថា ***វិស្ណុដៃ៨***។ លោកតាពជ្យចាប់ផ្តើមមានប្រជាប្រិយភាពក្រោយការជួសជុលរួចនាឆ្នាំ២០០៤-២០០៥ ហើយគេបានរៀបចំជាទីកន្លែងយ៉ាងស្អាត ខុសពីអ្នកតា៣ផ្សេងទៀត។ ការជឿលើលោកតាពជ្យ ធ្វើអោយប្រជាជនខ្មែរ និងបរទេសតែងតែធ្វើការបន់ស្រន់សុំសេចក្តីសុខ និងអោយជៀសផុតពីគ្រោះកាច ជំងឺឈឺថ្កាត់ផ្សេងៗ។ ជារៀងរាល់ឆ្នាំ ក្នុងខែមាឃ ប្រជាជនក្នុងតំបន់នានា ជុំវិញប្រាសាទអង្គរវត្តតែងតែមកប្រារព្ធពិធីឡើងមាឃនៅចំពោះមុខលោកតាពជ្យ ដោយមានរៀបចំគ្រឿងរណ្តាប់ បង្អែម ចម្អាប ផ្លែឈើ នំផ្សេងៗយ៉ាងច្រើនថ្វាយដល់លោកតាពជ្យ (រូបលេខ១២)។ នៅតំបន់ខ្លះ នៅពេលគេធ្វើពិធីសុំទឹកភ្លៀង[១០] គេតែងអន្ទងហៅអ្នកតាជាច្រើនមកចូលរូបស្នង និងសួរនាំពីមូលហេតុដែលមិនភ្លៀង ក្នុងនោះអ្នកតាលោកតាពជ្យក៏ត្រូវបានគេអញ្ជើញទៅសួរផងដែរ។

## ឯកសារយោង

សុខ កែវ សុវណ្ណារ៉ា, ២០២១:៣, *ពិធីសុំទឹកភ្លៀងអ្នកតំបន់អង្គរ*, ក្នុងAMS , ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា, ២០២១, *អាថ៌កំបាំងមឈ្ឈូលព្រះបាទសូរ្យវរ្ម័នទីនៅអង្គរវត្ត*, ក្នុង AMS , ភ្នំពេញ។

Jean Boisselier, 1966, *Asia du Sud-Est, Le Cambodge*, Tome I, EFEO, Pl. XXXI.

Peter Alan Robert and Tulku Yeshi, 2013, *The Noble Mahāyāna Sūtra " The Basket's Display"*, Vol.51.

---

[១០] សុខ កែវ សុវណ្ណារ៉ា, ២០២១:៣



រូបលេខ១៖ ចម្លាក់លោកតាពជ្យមុនឆ្នាំ១៩៤៩



រូបលេខ២៖ រុះរើលោកតាពជ្យក្នុងឆ្នាំ១៩៤៩



រូបលេខ៣៖ ព្រះវិស្ណុនៅប្រាសាទភ្នំដា



រូបលេខ៤៖ លោកតាពជ្យក្រោយជួសជុលឆ្នាំ២០០៤

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៥៖ បដិមាលោកេស្វរៈខាងត្បូងលោកតាពជ្យ



រូបលេខ២៦៖ បដិមាលោកេស្វរៈ



រូបលេខ២៧៖ បដិមាអវលោកិតេស្វរៈដៃ៨



រូបលេខ២៨៖ បដិមាអវលោកិតេស្វរៈដៃ១០

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ៩៖ បដិមាអវលោកិតេស្វរៈដៃនៅក្នុំដី



រូបលេខ១០៖ បដិមាអវលោកិតេស្វរៈដៃ៨



រូបលេខ១១៖ ចម្លាក់អវលោកិតេស្វរៈនៅបន្ទាយឆ្មារ



រូបលេខ១២៖ ពិធីឡើងមាយនៅមុខលោកតាពជ្យ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា